ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No :......296...........
Date:08..07..11.Time:9:50
For :....GMAC..........

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ:......526..........អ គ រ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១១

ជម្រាបមក

**អស់លោក លោកស្រីប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ ÷** ការសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ ។

**យោង ÷** - ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ ។

- ប្រកាសលេខ ៩០៦សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ។
- ស្មារតីកិច្ចប្រជុំយន្តការភាពជាដៃគូគយ-ផ្នែកឯកជនលើកទី៣ នាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកអស់លោក លោកស្រីថា ដើម្បីបង្កការងាយស្រួលបន្ថែមទៀតដល់វិនិយោគិន និងធុរជនពាក់ព័ន្ធជាពិសេសធុរជនដែលមានកម្រិតអនុលោមភាពខ្ពស់ក្នុងការបំពេញបែបបទគយស្របតាមស្មារតីនៃកិច្ចប្រជុំយន្តការភាពជាដៃគូគយ-ផ្នែកឯកជនលើកទី៣ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រេចកំណត់ និងកែសម្រួលលើនីតិវិធីគយមួយចំនួនដូចខាងក្រោម ÷

១- ផ្តល់អាទិភាពមិនបាច់រង់ចាំតាមជួរលំដាប់លំដោយ និងសម្រួលឱ្យបានជាអតិបរមាលើការបំពេញបែបបទគយតាមបទប្បញ្ញត្តិជាធរមានក្នុងការនាំចេញអង្ករ ។ ធុរជនពាក់ព័ន្ធ អាចផ្ទុកទំនិញចូលមធ្យោបាយដឹកជញ្ជូនដោយខ្លួនឯង រួចដឹកជញ្ជូនត្រង់សំដៅទៅមាត់ច្រកគយដើម្បីបំពេញបែបបទនាំចេញរួមទាំងការត្រួតពិនិត្យដោយម៉ាស៊ីនស្កេននៅទីនោះតែម្តង ដោយពុំតម្រូវឱ្យមានការសុំការអនុញ្ញាតនាំចេញជាមុនឡើយ ។

២- អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ ត្រូវជម្រុញប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិគយជាធរមាន កាត់បន្ថយអំពើរត់គេចពន្ធបន្ថែមទៀតតាមរយៈការតម្រូវឱ្យបំពេញកាតព្វកិច្ចពន្ធអាករ និងការត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើការនាំចូលទំនិញគ្រប់ប្រភេទជាពិសេសមុខទំនិញអង្ករ និងមីកញ្ចប់ដែលជាផលិតផលអាចផលិតបានក្នុងស្រុក ។

៣- លើកលែងតែមានការសម្រេចដោយឡែកផ្សេងពីនេះ សម្រាប់បណ្តាទំនិញដែលដឹកជញ្ជូនក្រោមរបបឆ្លងកាត់គយ (Customs Transit Procedure) តាមបទប្បញ្ញត្តិជាធរមាន ដោយផ្ទុកក្នុងកុងតឺន័រដែលមានមាឌយ៉ាងតិច១ម៉ែត្រគូប និងអាចបិទត្រាឬសៀលគយបានប្រកបដោយសុវត្ថិភាព អាចស្ថិតក្រៅនីតិវិធីគយនៃការអមទំនិញដោយមន្ត្រីគយមានសមត្ថកិច្ច ។

៤- អង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចត្រួតពិនិត្យបែបបទគយ មានកាតព្វកិច្ចទទួលស្គាល់ជាបណ្តោះអាសន្ននូវឯកសារនានាដូចខាងក្រោមដែលបញ្ជូនតាមទូរសារ (Facsimile) ÷

- លិខិតអនុញ្ញាតគយនាំចូលរបស់វិនិយោគិនវិស័យកាត់ដេរ និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស ។
- លិខិតអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់គ្រប់ប្រភេទរបស់ប្រតិបត្តិករសន្និធិគយបណ្តោះអាសន្នឬឃ្លាំងគយមានដែនកំណត់ ។
- លិខិតអនុញ្ញាតផ្សេងទៀតដែលមានការអះអាងជាលាយលក្ខអក្សរពីជើងសារគយមាននីតិសម្បទា ដែលបានតម្កល់និមុត្តិជានារូច និងជាប្រតិវេទករ ។

ធុរជនពាក់ព័ន្ធ ឬតំណាងត្រូវតម្កល់ច្បាប់ដើមនៃឯកសារសងវិញក្នុងរយៈពេលមិនលើស ១៥ថ្ងៃ ។

៥- រាល់ឯកសារនានាដែលត្រូវបានសម្រេចរួចដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រាប់ការអនុវត្តបំពេញបែបបទគយនៅអង្គភាពតាមមាត់ច្រកព្រំដែនឬការិយាល័យបំពេញបែបបទគយផ្សេងទៀត ពុំតម្រូវឱ្យមានការចូលចារបញ្ជាក់នៅតាមសាខាគយនិងរដ្ឋាករពាក់ព័ន្ធទៀតឡើយ ។ ក្នុងករណីចាំបាច់ សាខាគយនិងរដ្ឋាករពាក់ព័ន្ធ អាចចាត់មន្ត្រីគយជាតំណាងប្រចាំការនៅទីស្នាក់ការគយមាត់ច្រក ដើម្បីប្រមូលនិងបញ្ជូនព័ត៌មាន ឬឯកសារទាំងនេះមកសាខាគយនិងរដ្ឋាករពាក់ព័ន្ធឱ្យបានទៀងទាត់និងជាបន្ទាន់សម្រាប់សំណូមពរការងារគយផ្សេងៗ ។

៦- សម្រាប់ការនាំចូលធាតុចូលរបស់វិនិយោគិនវិស័យកាត់ដេរ និងវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រោមប្រព័ន្ធបញ្ជីមេដែលចេញដោយស្ថាប័នមានសមត្ថកិច្ចនានា តម្លៃទំនិញនាពេលបំពេញបែបបទគយសុំលិខិតអនុញ្ញាតនាំចូលឬបញ្ចេញទំនិញពីគយ ត្រូវទទួលយកជាបណ្តោះអាសន្នតាមតម្លៃក្នុងវិក្កយបត្រដែលបានប្រកាសដោយធុរជនដែលជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដោយមិនកម្រិតពីភាពលម្អៀងរវាងតម្លៃដែលបានប្រកាស និងតម្លៃក្នុងបញ្ជីមេ ។

៧- អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ ជាពិសេសសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវគោលការណ៍អ្នកមកមុនត្រូវផ្តល់សេវាមុន (First in - First out Principle) លើកលែងតែប្រតិបត្តិការនាំចេញនាំចូលមួយចំនួនដែលផ្តល់អាទិភាពធ្វើបែបបទគយជូនមុនរួមទាំងការឆ្លងម៉ាស៊ីនស្កេនដូចជា÷

- ប្រតិបត្តិការនាំចេញអង្ករ ឬសំលៀកបំពាក់ ។
- ការនាំចូលរបស់ធុរជនដែលមានកម្រិតអនុលោមភាពខ្ពស់តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលអាចជាវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស ឧស្សាហកម្មកាត់ដេរ និងប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (AEO) ដែលអាចនឹងត្រូវបង្កើតជាយថាហេតុ ជាដើម ។
- ការបំពេញបែបបទនាំចេញនាំចូលទំនិញគ្រប់ប្រភេទដែលមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចយល់ថាមានលក្ខណៈបន្ទាន់ដូចជា ត្រូវផ្ទុកចូលនាវាភ្លាមព្រោះដល់ពេលចេញដំណើរ ឬសំណូមពរចាំបាច់ផ្សេងទៀត ។

ទទួលបានលិខិតនេះ សូមអស់លោក លោកស្រីចាត់ចែងអនុវត្តតាមមុខការរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីពេលនេះតទៅ ។

សូមអស់លោក លោកស្រីទទួលនូវការស្រលាញ់រាប់អានពីខ្ញុំ ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

**បណ្ឌិត.ប៉ែន_ស៊ីម៉ន**

**ចម្លងជូន÷**

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  និងជាអ្នកសម្របសម្រួលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- គ្រប់សមាជិកនៃសមាសភាពដឹកនាំ
  យន្តការភាពជាដៃគូគយ-ផ្នែកឯកជន
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC)
- សមាគមដឹកជញ្ជូនកម្ពុជា
- សមាគមអ្នកបញ្ជូនទំនិញកម្ពុជា
  "ដើម្បីជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ